រដ្ឋបាលខេត្តត្បូងឃ្មុំ
លេខៈ ៥៤០/[illegible].ភយ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃភាស៊ីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥

**យោង៖** លិខិតលេខ១០៦២៣សហវ.អទច ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីស្នើសុំរៀបចំដាក់ឱ្យដេញថ្លៃភាស៊ីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិការាជធានី ខេត្ត។

**រដ្ឋបាលខេត្តត្បូងឃ្មុំ** សូមជម្រាបជូនដល់អាជីវករ និងសាធារណៈជនទាំងអស់ ឱ្យបានជ្រាបថា រដ្ឋបាលខេត្តនឹងរៀបចំការដេញថ្លៃភាស៊ីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មទូទាំងខេត្តត្បូងឃ្មុំ ដែលមាន ភាស៊ីផ្សារចំនួន ៣ទីតាំង ដូចខាងក្រោម៖

១. ផ្សារទន្លេបិទ ស្ថិតនៅឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

២. ផ្សារព្រែកចាម ស្ថិតនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

៣. ផ្សារចុងជាច ស្ថិតនៅឃុំចុងជាច ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

**ទីកន្លែងដេញថ្លៃ ៖** នៅសាលប្រជុំជាន់ទី២ នៃអគារមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ស្ថិតនៅភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

**កាលបរិច្ឆេទដេញថ្លៃ ៖** ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ៩:០០ នាទី។

**កាលបរិច្ឆេទឈប់ទទួលពាក្យ ៖** ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ វេលាម៉ោង ១៥:០០ នាទី។

**លក្ខខណ្ឌនៃការធ្វើអាជីវកម្ម និងចូលរួមដេញថ្លៃ៖**

### I. ការធ្វើអាជីវកម្ម

១.រយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

២.តម្លៃមូលដ្ឋានភាស៊ី

| | | |
|---|---|---|
| - ផ្សារទន្លេបិទ | ១ ៥០០ ០០០ រៀល | ក្នុង ១ឆ្នាំ |
| - ផ្សារព្រែកចាម | ១ ៦០០ ០០០ រៀល | ក្នុង ១ឆ្នាំ |
| - ផ្សារចុងជាច | ១ ២៥០ ០០០ រៀល | ក្នុង ១ឆ្នាំ |



អាសយដ្ឋាន : ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (855) 45 211 118
Nikom Leu Village, Smlab Commune, Tboung Khmum District, Tboung Khmum Province, Cambodia. E-mail : admin@tboungkhmum.gov.kh Web : www.tboungkhmum.gov.kh

៣.ការដេញថ្លៃ ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃឡើង។

## II. លក្ខខណ្ឌចូលរួមដេញថ្លៃ

១.ពលរដ្ឋគ្រប់រូប មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មានសិទ្ធចូលរួមដេញថ្លៃទាំងអស់ "លើកលែងតែមន្ត្រីរាជការ សិស្ស និស្សិត កងកំលាំងប្រដាប់អាវុធ" ។

២.អ្នកដាក់ពាក្យចូលរួមដេញថ្លៃ ត្រូវបង់ប្រាក់កក់បណ្តោះអាសន្នចំនួន ២០% នៃតម្លៃមូលដ្ឋាន តាមរយៈគណនីរបស់រតនាគារខេត្តត្បូងឃ្មុំ នៅសាខាធនាគារអេស៊ីលីដា៖

- ផ្សារទន្លេបិទ ២០% = ៣០០ ០០០ រៀល
- ផ្សារព្រែកចាម ២០% = ៣២០ ០០០ រៀល
- ផ្សារចុងដាច ២០% = ២៥០ ០០០ រៀល

៣.អ្នកដាក់ពាក្យចូលរួមដេញថ្លៃ ត្រូវតម្កល់ ធនធាន(ប្រាក់រៀល) ឬអចលនវត្ថុធានាចំនួន ៥០% នៃតម្លៃមូលដ្ឋាន។ ចំពោះអចលនវត្ថុធានា ត្រូវមានការវាយតម្លៃបញ្ជាក់ពីចៅសង្កាត់ ឬមេឃុំ ហើយអចលនវត្ថុធានាជាកម្មសិទ្ធិរបស់អាជីវករផ្ទាល់ មិនអនុញ្ញាតឱ្យយកកម្មសិទ្ធិអ្នកដទៃជំនួសឡើយ ហើយត្រូវមានការទទួលស្គាល់ពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤.អ្នកដាក់ពាក្យសុំចូលរួមដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវ៖

- ពាក្យសុំចូលរួមដេញថ្លៃ ចំនួន ២ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ចំនួន ២ច្បាប់
- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ច្បាប់
- រូបថត ៤ x ៦ ចំនួន ២សន្លឹក
- កិច្ចសន្យាស្តីពីការប្រគល់ប្រាក់កក់បណ្តោះអាសន្ននិងពិន័យជូនរដ្ឋ ចំនួន ២ច្បាប់
- កិច្ចសន្យាស្តីពីការប្រគល់ប្រាក់ធានាស្តារជូនរដ្ឋ ចំនួន ២ច្បាប់
- កិច្ចសន្យាស្តីពីការប្រតិបត្តិតាមសៀវភៅបន្ទុក ចំនួន ២ច្បាប់
- លិខិតធានា ប្រាក់កក់ធានាការដេញថ្លៃ(ប្រាក់កក់បណ្តោះអាសន្ន ២០% នៃតម្លៃមូលដ្ឋាន) ចេញដោយរតនាគារខេត្តត្បូងឃ្មុំ ចំនួន ២ច្បាប់
- បង្កាន់ដៃប្រគល់ទទួល តម្កល់ធនធាន ឬអចលនវត្ថុធានា ៥០% នៃតម្លៃមូលដ្ឋាន ចំនួន ២សន្លឹក
- បង្កាន់ដៃទទួលពាក្យដេញថ្លៃភាស៊ីសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ ចំនួន ២សន្លឹក

៥.ពាក្យសុំចូលរួមដេញថ្លៃ និងព័ត៌មានផ្សេងៗ សូមអញ្ជើញមកទំនាក់ទំនងដោយផ្ទាល់នៅការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ជាន់ទី២ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ស្ថិតនៅភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ទទួលបានសេចក្តីជូនដំណឹងខាងលើ សូមអាជីវករ និងសាធារណៈជនទាំងអស់ ជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមដាក់ពាក្យដេញថ្លៃភាស៊ីតាមទីតាំង និងកាលបរិច្ឆេទខាងលើឱ្យបានទាន់ពេលវេលាកំណត់។

ថ្ងៃ.ចន្ទ.១១.កើត.ខែ.កត្តិក...ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅខេត្តត្បូងឃ្មុំ ថ្ងៃទី.១១....ខែ.វិច្ឆិកា...ឆ្នាំ២០២៤

**អភិបាលខេត្ត**

ប៉ែន កុសល្យ

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីគោរពជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ